អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

**អង្គភាពគាំពារជនរងគ្រោះ**
**Victims Support Section**
**Section d'appui aux victimes**

ភ្នំពេញ ថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៤

# សេចក្តីប្រកាសព័ត៌មាន

## ការចាប់ផ្តើមធ្វើផែនការសម្រាប់ការស្នើសុំគម្រោងសំណង សំណុំរឿង០០២/០២

សំណើសុំចុងក្រោយរបស់ដើមបណ្តឹងរដ្ឋប្បវេណីស្តីពីសំណង ក្នុងសំណុំរឿង០០២/០១ ត្រូវបានដាក់ដោយជោគជ័យ នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) នាពេលកន្លងមក។ ការរៀបចំបង្កើតសំណើស្តីពីគម្រោងសំណងសម្រាប់សវនាការបន្ទាប់ក្នុងសំណុំរឿង ០០២/០២ នឹងត្រូវចាប់ផ្តើម។ អង្គភាពគាំពារជនរងគ្រោះ និងអង្គភាពសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី នឹងពិគ្រោះយោបល់ជាមួយដើមបណ្តឹងរដ្ឋប្បវេណី មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី អង្គការសង្គមស៊ីវិល សមាគមជនរងគ្រោះ អាជ្ញាធរ និងម្ចាស់ជំនួយដើម្បីកំណត់ និងពិភាក្សាលើសំណើស្តីពីគម្រោងសំណងដែលមានសក្តានុពល សម្រាប់ជាប្រយោជន៍របស់ជនរងគ្រោះនៃអតីតរបបខ្មែរក្រហម។

ដើម្បីត្រៀមរៀបចំសម្រាប់សវនាការបន្ទាប់ អង្គភាពសហមេធាវីនាំមុខ និងអង្គភាពគាំពារជនរងគ្រោះ នឹងរៀបចំកិច្ចពិគ្រោះយោបល់អំពីសំណងក្នុងសំណុំរឿង ០០២/០២ ជាមួយអ្នកពាក់ព័ន្ធទាំងអស់ស្តីពីបទពិសោធន៍មេរៀនល្អៗ និងការដាក់ផែនការជាជំហានបន្ទាប់ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៤ ចាប់ពីម៉ោង ៨ព្រឹក ដល់ ៥ល្ងាច នៅមជ្ឈមណ្ឌលព័ត៌មានកិច្ចឯកភាពគ្រិស្តបរិស័ទភ្នំពេញ ផ្ទះលេខ១៩-២១ ផ្លូវ៣៣០ សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន រាជធានីភ្នំពេញ។

ព្រឹត្តិការណ៍នេះនឹងមានការចូលរួមពីអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីពិភាក្សាគ្នាអំពីការអនុវត្តល្អៗ និងបទពិសោធន៍ទទួលបាននាពេលកន្លងមកក្នុងវិស័យសំណងនៅចំពោះមុខ អ.វ.ត.ក ដើម្បីចាប់ផ្តើមគម្រោងសំណងដែលស្នើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២/០២។ ឧក្រិដ្ឋកម្មជាច្រើនដែលនឹងត្រូវដាក់បញ្ចូលនៅក្នុង

សវនាការ ០០២/០២ មានដូចជា៖ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និង ឧក្រិដ្ឋកម្មសង្គ្រាម។ អង្គភាពគាំពារជនរងគ្រោះ និងអង្គភាពសហមេធាវីនាំមុខ នឹងស្វះស្វែងបង្កើតឲ្យមាន សំណើផ្សេងៗពាក់ព័ន្ធទៅនឹងព្យសនកម្មដែលជាផលវិបាកនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ និងបង្កើតឲ្យមាន សំណងដល់ដើមបណ្តឹងរដ្ឋប្បវេណី។

កិច្ចពិគ្រោះយោបល់អំពីសំណងសម្រាប់សំណុំរឿង ០០២/០២ បន្ទាប់ទៀត នឹងត្រូវបន្តធ្វើជាមួយដើមបណ្តឹង រដ្ឋប្បវេណីក្នុងសំណុំរឿង០០២ ដោយចាប់ផ្តើមពីការរៀបចំធ្វើសិក្ខាសាលាស្តីពីសំណងក្នុងសំណុំរឿង ០០២/០២ ដែលនឹងគ្រោងធ្វើឡើងនៅខែខាងមុខ នៅរាជធានីភ្នំពេញ។ ព្រឹត្តិការណ៍នេះនឹងមានការចូល រួមដោយដើមបណ្តឹងរដ្ឋប្បវេណីជាច្រើននាក់មកពីទូទាំងប្រទេសកម្ពុជាដើម្បី កំណត់ ពិភាក្សា និងលើកជាសំណើស្តីពីគម្រោងសំណងសម្រាប់សំណុំរឿង ០០២/០២។

ដោយឈរលើទស្សនៈនៃការពិគ្រោះយោបល់ប្រកបដោយអត្ថន័យ ការធ្វើនិងអនុវត្តគម្រោងប្រកប ដោយ ប្រសិទ្ធភាព និងប្រសិទ្ធផល សម្រាប់ផលប្រយោជន៍ទូលំទូលាយដល់ជនរងគ្រោះនៃអតីតរបប ខ្មែរក្រហម អ្នកពាក់ព័ន្ធទាំងអស់ដែលមានចំណាប់អារម្មណ៍ស្តីពីគម្រោងសំណងនៅចំពោះមុខអ.វ.ត.ក ត្រូវ បានស្វាគមន៍ដើម្បីចូលរួមនៅក្នុងដំណើរការនេះ។ សូមទាក់ទង **លោក ជា សុភ័ក្រ្ត** (ទូរស័ព្ទលេខ ០១២ ៩២២ ២៧៤) ដើម្បីបញ្ជាក់ពីការចូល។ អ្នកសារព័ត៌មាននឹងត្រូវអនុញ្ញាតឲ្យចូលរួមតែវគ្គដំបូង និងវគ្គចុងក្រោយនៃ កម្មវិធីនេះ ចំណែកឯវគ្គផ្សេងទៀតទុកសម្រាប់តែអ្នកចូលរួមធម្មតាតែប៉ុណ្ណោះ។ អ្នកតំណាងសារព័ត៌មានដែល មានបំណងចូលរួមនៅក្នុងព្រឹត្តិការណ៍នេះ សូមទាក់ទងមន្ត្រីទទួលបន្ទុកពត៌មានដែលមានរាយនាមនៅខាង ក្រោម។

ដើមបណ្តឹងរដ្ឋប្បវេណីអាចទាមទារសំណងជាលក្ខណៈសមូហភាពនិងផ្លូវចិត្តបាន។ គម្រោងសំណងគឺធ្វើឡើង ដោយសមស្របទៅតាមពិរុទ្ធភាពរបស់ជនជាប់ចោទ ដែលត្រូវបានគេសន្មតថាគ្មានទោសរហូតដល់ការប្រកាស សាលដីកាស្ថាពរនៃការជំនុំជម្រះក្តីចុងក្រោយ។

អង្គភាពគាំពារជនរងគ្រោះ ជាអង្គភាពផ្លូវការមួយរបស់ អ.វ.ត.ក ហើយមានភារកិច្ចសម្របសម្រួលឲ្យ ជនរងគ្រោះចូលរួមនៅក្នុងដំណើរការនីតិវិធី អ.វ.ត.ក។ លើសពីនេះ អង្គភាពគាំពារជនរងគ្រោះ ដោយសហ ការយ៉ាងជិតស្និទ្ធជាមួយ អង្គភាពសហមេធាវីនាំមុខ មានភារកិច្ចកំណត់ រៀបចំ និងអនុវត្តគម្រោងសំណង និង ស្វែងរកមូលនិធិ និងជំនួយជ្រោមជ្រែងដល់ការងារសំណង ។

| ទំនាក់ទំនងនៅអង្គភាពគាំពារជនរងគ្រោះ | ទំនាក់ទំនងនៅអង្គភាពសហមេធាវីនាំមុខ |
|---|---|
| លោក ហង្ស វណ្ណៈ ប្រធានអង្គភាពគាំពារជនរងគ្រោះ<br>សារអេឡិចត្រូនិក៖ hang.vannak@eccc.gov.kh<br><br>លោក TRUEMPER Thomas ទីប្រឹក្សា ភ្នាក់ងារសហប្រតិបត្តិការអាល្លឺម៉ង់ (GIZ) នៃកម្មវិធីសេវាសន្តិភាពស៊ីវិល<br>សារអេឡិចត្រូនិក៖ truemper.thomas@eccc.gov.kh | លោក ពេជ អង្គ សហមេធាវីនាំមុខ នៃអង្គភាពសហមេធាវីនាំមុខ<br>សារអេឡិចត្រូនិក៖ pich.ang@eccc.gov.kh<br>កញ្ញា Katrina NATALE ទីប្រឹក្សាផ្នែកច្បាប់នៃអង្គភាពសហមេធាវីនាំមុខ<br>សារអេឡិចត្រូនិក៖ natale.katrinamarie@eccc.gov.kh |

## ចំពោះពត៌មានពិស្តារសូមទាក់ទង៖


លោក នេត្រ ភក្ត្រា
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទដៃលេខ៖ ៨៥៥ (0) ១២ ៤៨៨ ១៥៦
ទូរស័ព្ទលើតុលេខ៖ ៨៥៥ (0) ២៣ ៨៦១ ៥៦៤
សារអេឡិចត្រូនិក៖ neth.pheaktra@eccc.gov.kh

លោក ឡាស អូលសិន
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរស័ព្ទដៃលេខ៖ ៨៥៥ (0) ៤៨៨ ០២៣
ទូរស័ព្ទលើតុលេខ៖ ៨៥៥ (0) ២៣ ៨៦១ ៦៦៩
សារអេឡិចត្រូនិក៖ olsenl@un.org